ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខាធិការដ្ឋានរដ្ឋបាលសរុប

# កំណត់ហេតុកិច្ចប្រជុំពិភាក្សា
# ស្ដីពីករណីអំពើធ្វើអន្តរកាវី នៃអំពើពពោះ

សាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែវិច្ឆិកា ថ្ងៃទីម្ភៃបួន វេលាម៉ោងប្រាំបួន និងសាមសិបនាទី នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សាលើករណីអំពើធ្វើអន្តរកាវី នៃអំពើពពោះ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធមួយចំនួនដូចខាងក្រោម៖

១.អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

២.តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៣.តំណាងក្រសួងសុខាភិបាល

៤.តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៥.តំណាងក្រសួងកិច្ចការនារី

៦.តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ

៧.លោក វរសេនីយ៍ឯក កែវ ជា នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

៨.លោក សេង ហៀង ព្រះរាជអាជ្ញារង សាលាដំបូងរាជធានីភ្នំពេញ

៩.តំណាងស្ថានទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា

១០.តំណាងអង្គការ APLE, HAGAR, MFA, Children in Family

ជាកិច្ចចាប់ផ្ដើម លោកជំទាវ ជូ ប៊ុនអេង បានមានមតិស្វាគមន៍យ៉ាងកក់ក្ដៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមាននាពេលនេះ។ បន្ទាប់មកលោកជំទាវ បានអនុញ្ញាតឲ្យលោក **វរសេនីយ៍ឯក កែវ ជា** ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ឡើងធ្វើសេចក្ដីរាយការណ៍សង្ខេបអំពីករណីពពោះ ដែលការិយាល័យជំនាញបានបង្ក្រាបនាពេលកន្លងមក ជូនសមាជិកអង្គប្រជុំ។

មតិរបស់ លោកវរសេនីយ៍ឯក កែវ ធា៖ ចំពោះសកម្មភាពធ្វើអន្តរការី នៃអំពើពពោះនេះ គឺកើតមានកន្លងមកហើយសម្រាប់ព្រះរាជាណាចក្រកម្ពុជាយើង ដោយកើតឡើងតាមរយៈមេខ្យល់ដែលបានអូសទាញលើស្ត្រីមានគ្រួសារក្រីក្រស់នៅតាមជនបទ។ ករណីនេះយើងធ្វើការបង្ក្រាបបានដោយមានការសហការជាមួយព្រះរាជអាជ្ញារង សេង ហៀង នៃសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការឃាត់ខ្លួនមនុស្សចំនួន ០៣នាក់ (ប្រុស០១នាក់ និងស្រី ០២នាក់) ក្នុងនោះមានស្ត្រីជាជនជាតិអូស្ត្រាលីម្នាក់ផងដែរ។ តាមការឆ្លើយបំភ្លឺរបស់ស្ត្រីពពោះបានឲ្យដឹងថា៖ ក្នុងរយៈពេលពពោះ ១ខែត្រូវបានគេឧបត្ថម្ភថវិកាចំនួន ៤០០ដុល្លារសហរដ្ឋអាមេរិក ហើយពេលសម្រាលកូនរួចគេផ្តល់ជូនគាត់ចំនួន ១០០០០ដុល្លារសហរដ្ឋអាមេរិកទៀត។ បើពិនិត្យតាមក្រមព្រហ្មទណ្ឌឃើញថា៖ ពួកគាត់ទាំង ០៣នាក់ ជាប់ចោទតាមមាត្រា ៣៣២ និងមាត្រា៦៣២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។ ករណីនេះការិយាល័យជំនាញកំពុងដំណើការទៅតាមនីតិវិធិ និងកំពុងធ្វើការស៊ើបអង្កេតស្រាវជ្រាវបន្តទៀតរាល់ឯកសារពាក់ព័ន្ធលើករណីនេះ។

បន្ទាប់មកទៀត **លោកជំទាវ ជូ ប៊ុនអេង** មានប្រសាសន៍ពាក់ព័ន្ធលើករណីនេះ ហេតុអ្វីបានជា គ.ជ.ប.ជ ខ្វាយខ្វល់យ៉ាងដូចនេះ? ទោះបីរឿងនេះមានលក្ខណៈជាមនុស្សធម៌ក៏ដោយ។ បើតាមការស៊ើបអង្កេតបានឲ្យដឹងថា មានស្ត្រីពពោះចំនួន២៣នាក់ហើយ តើនៅមានចំនួនប៉ុន្មាននាក់ទៀតដែលយើងពុំទាន់បានដឹង? កិច្ចព្រមព្រៀងជាមួយគ្នា យើងក៏ពុំទាន់បានធ្វើចំពោះរឿងនេះ បើគាត់មានបញ្ហា តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការពពោះរបស់គាត់? ដូចនេះគួរជួយស្រាវជ្រាវបន្ថែមទៀតដោយសហការជាក្រសួង ស្ថាប័ន អយ្យការ ព្រះរាជអាជ្ញា ក្នុងការប្រមូលភស្តុតាង ឯកសារពាក់ព័ន្ធ តើការប្រព្រឹត្តនេះវាជាបទល្មើសអី? អ្នកយកកម្រៃជើងសារពីបទល្មើស និងមានទោសអី? ប្រទេសមួយចំនួនអាចស្របច្បាប់ចំពោះអ្នកពពោះ។ សម្រាប់ស្ត្រីដែលបានពពោះហើយៗ នៅពេលដែលកូនកើតចេញមក តើកូននោះត្រូវយកទៅណា? បើរឿងនេះជួបបញ្ហា? ដោយឡែកស្ត្រីពពោះនោះច្រើនតែស្ត្រីដែលមានជីវភាពក្រីក្រនៅតាមជនបទ។ មានស្ត្រីចំនន១៨នាក់ ទៀតដែលកំពុងមានគភ៌រួចទៅហើយ តើយើងត្រូវមានវិធានការយ៉ាងដូចម្តេច ក្នុងការជួយដោះស្រាយជូនគាត់?

មតិលោក **ហ៊ើ សុធា** អនុប្រធានការិយាល័យក្រសួងសុខាភិបាល ច្បាប់គ្រប់គ្រងកោសិកា មេជីវិតយើងមានរួចហើយ។ ការបរិចាកមេជីវិតមានលក្ខណៈពាណិជ្ជកម្ម ហើយច្រើនកើតមាននៅតាមគ្លីនិកឯកជន វាជាការខុសច្បាប់រួចទៅហើយ។ អ្នកដែលពពោះដើម្បីទទួលប្រាក់ពីការបញ្ចូលមេជីវិតនោះ គឺវាខុសច្បាប់ដែរ។ ខាងសមត្ថកិច្ចនគរបាលដែលបានធ្វើការងារនេះមានការពាក់ព័ន្ធគ្រប់ដណ្តប់ដោយច្បាប់ពីរ។

មតិតំណាងស្ថានទូតអូស្ត្រាលី៖ យើងមានការចាប់អារម្មណ៍ពីការស៊ើបអង្កេតក្នុងរឿងពពោះ និងព័ត៌មានថ្មីៗ ចេញដោយក្រសួងសុខាភិបាល ដោយមានស្ត្រីជនជាតិអូស្ត្រាលីម្នាក់ត្រូវបានចាប់ខ្លួនពាក់ព័ន្ធក្នុងរឿងនេះ។ តាមទស្សនៈស្ថានទូតអូស្ត្រាលី ការអនុវត្តច្បាប់ពពោះនោះ តើមានការពាក់ព័ន្ធយ៉ាងណាដែរជាមួយជនជាតិអូស្ត្រាលីរូបនោះ។ គួរមានការពពោះជាលក្ខណៈអន្តរជាតិ ដំណើការវិធានការ នៃការពពោះយើងនឹងមានការពិភាក្សាជាបន្តទៀត មុននឹងបញ្ជាក់ជូនការផ្តល់តំណរពូជន៍ ពីឪពុកទៅកូននោះហេតុអីការស្នុំកូនពាក់ព័ន្ធរឿងនេះ? ការស្នើសុំទិដ្ឋាការមានការពាក់ព័ន្ធផ្នែកជីវសាស្ត្រ។ រដ្ឋាភិបាលអូស្ត្រាលីមានការគ្រប់គ្រងការស្នុំកូននៅក្រៅ

ប្រទេស ប៉ុន្តែពុំមានការស៊ើកូនរបស់ជនជាតិអូស្ត្រាលីនៅក្រៅប្រទេសជាលក្ខណៈឯកជនទេ។

មតិរបស់ លោក សេង ហៀង ព្រះរាជអាជ្ញារងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចំពោះករណីនេះ យើងពុំអាចកំណត់បទល្មើសបាននៅឡើយទេ តែបើពិនិត្យទៅលើអង្គហេតុវិញករណីនេះជាប់ពាក់ព័ន្ធក្នុងការក្លែងឯកសារ ការចូលសញ្ជាតិ និងឯកសារមួយចំនួនទៀតជាដើម។ ដូចនេះអ្វីដែលយើងសំណូមពរដល់ពួកគាត់នោះគឺសូមឲ្យធ្វើឯកសារមានលក្ខណៈស្របច្បាប់ និងត្រូវឲ្យពួកគាត់ធ្វើដោយមានការទទួលស្គាល់ពីស្ថាប័នតុលាការជាមុនសិន ទើបពួកគាត់អាចរួចផុតពីការចោទប្រកាន់បាន។

មតិរបស់ លោក អ៊ុន ចាន់ថុល មេធាវីអង្គការ APLE នៅមានការព្រួយបារម្ភច្រើនត្រូវរកវិធានការជាបណ្ដោះអាសន្នមួយសិន ព្រោះច្បាប់ស្ដីពីការធ្វើអន្តរការី នៃអំពើពពោះព្រះរាជាណាចក្រកម្ពុជាយើងពុំទាន់មានទេ។ ដូចនេះ យើងត្រូវឲ្យខាងអូស្ត្រាលីបញ្ឈប់លើរឿងនេះមួយរយៈពេលសិន បើយកល្អគួរឲ្យចំនួនអ្នកចង់បានកូនដោយរបៀបនេះធ្វើការកំណត់ឲ្យបានច្បាស់លាស់ តើមានចំនួនប៉ុន្មាននាក់? យើងធ្វើដូចនេះទើបធ្វើការដោះស្រាយបាន ហើយត្រូវធ្វើទៅតាមលក្ខណៈច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាយើង។ យើងត្រូវបង្កើត គណៈកម្មការមួយលើករណីនេះដើម្បីរកវិធានការដោះស្រាយរួមគ្នាមួយ ជាមួយភាគីអូស្ត្រាលី កុំឲ្យស្ត្រីដែលកំពុងមានគភ៌មួយចំនួនទៀតជួបនូវការលំបាកពិសេសនៅពេលកូនបានកើតចេញមក តើអ្នកណាជាអ្នកដោះស្រាយ និងទទួលខុសត្រូវ?

មតិរបស់ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន យើងគួរបង្កើតគណៈកម្មការមួយចំពោះករណីនេះ និងសូមឲ្យខាងអូស្ត្រាលី ផ្អាកសិនចំពោះការធ្វើទិដ្ឋាការផ្ដល់សញ្ជាតិដល់ក្មេងដែលត្រូវយកទៅរស់នៅអូស្ត្រាលីនោះ។ មួយទៀតពិនិត្យលើឯកសារឃើញថា៖សុទ្ធតែក្លែងក្លាយទៀត។

ប្រសាសន៍ **លោកជំទាវ ជូ ប៊ុនអេង** ឥលូវនេះសូមឲ្យភាគីអូស្ត្រាលីធ្វើការសហការគ្នាជាមួយកម្ពុជាក្នុងការបង្កើតគណៈកម្មការមួយដើម្បីដោះស្រាយលើករណីនេះ ធ្វើយ៉ាងណាឲ្យមានការព្រមព្រៀង និងឯកភាពគ្នាសិន ជៀសវាងកុំឲ្យកូននៅក្នុងផ្ទៃ ពេលកើតចេញមកជួបនូវបញ្ហានាថ្ងៃក្រោយ ព្រោះអីស្ត្រីពពោះនោះ គេពុំទទួលយកកូនដែលបានកើតចេញមកយកទៅចិញ្ចឹមនោះទេ។ ខ្ញុំនឹងសុំគោលការណ៍មួយពី **សម្ដេចក្រឡាហោម សខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ សិន ហើយយើងត្រូវធ្វើទៅតាមនីតិវិធីមួយជាបណ្ដោះអាសន្ន ដោយធ្វើការជាមួយអូស្ត្រាលី។ សូមឲ្យសមត្ថកិច្ចជំនាញអនុវត្តទៅតាមនីតិវិធីបន្តហើយភាគីអូស្ត្រាលី ត្រូវពិនិត្យឲ្យបានច្បាស់លាស់ហ្មត់ចត់បំផុត។ ចំពោះស្ត្រីកំពុងពពោះចំនួន២៣នាក់នោះ សូមឲ្យពួកគាត់នាំយកបុរស ស្ត្រីដែលចង់បានកូនមកបង្ហាញខ្លួនឲ្យបានគ្រប់គ្នា។

កិច្ចប្រជុំពិភាក្សានេះបានបញ្ចប់នៅវេលាម៉ោងដប់ពីរ និងដប់ប្រាំនាទីថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល។

ឃ្លាំង ០១/១២/២០១៦

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦

**អ្នកធ្វើកំណត់ហេតុ**

ទិត ឥន្ទ្រា

គោរពជូន

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦

ជូ ប៊ុនអេង

ប្រធានលេខាធិការដ្ឋានរង

ឧត្តមសេនីយ៍ត្រី ឆាន់ . . .

**សមាសភាពចូលរួមកិច្ចប្រជុំពិភាក្សា**
**ស្ដីពីករណីអំពើធ្វើអន្តរភាវី នៃអំពើពពោះ**
សាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦

| | | |
|---|---|---|
| ១.លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃ គ.ជ.ប.ជ |
| ២.ឯ.ឧ ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៣.ឯ.ឧ ឧ.ឯក | ប៉ុល កិរេយ្យ | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ៤.ឯ.ឧ ឧ.ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៥.ឯ.ឧ ឧ.ឯក | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៦.ល.ជំ ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៧.លោក | ហួន ទីម | អង្គការ APLE |
| ៨.លោក | MIKE NOWLIN | Executive Director ( HAGAR ) |
| ៩.លោកស្រី | សេង ដាណែត | ប្រធានធនធានមនុស្ស ( HAGAR ) |
| ១០.លោកស្រី | កែវ រ៉ាវី | ប្រធានអង្គការ Children in Family |
| ១១.លោក | ខឹម វ៉ាន់ដូ | នាយកកម្មវិធី APLE |
| ១២.លោក | សំនៀង សីលា | នាយកប្រតិបត្តិ APLE |
| ១៣.លោក | អ៊ុន ច័ន្ទថុល | មេធាវី APLE |
| ១៤.លោក | ណុប រដ្ឋា | ប្រធានការិយាល័យ MFA |
| ១៥.លោក | លី សុវិច្ឆ័យ | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ១៦.លោក ឧ.ត្រី | គង់ ពុទ្ធី | ប្រធាលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៧.លោក ឧ.ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន កិច្ចការយុត្តិធម៌ គ.ជ.ប.ជ |
| ១៨.លោក | តែ សុថារ៉េត | អនុប្រធាននាយកដ្ឋានអនុវត្តច្បាប់ គ.ជ.ប.ជ |
| ១៩.លោក | ឈា សុវណ្ណ | ប្រធានវិទ្យាស្ថានសុខភាពសាធារណៈ |
| ២០.លោកស្រី | ជា សុម៉ាលី | ប្រធានការិយាល័យកិច្ចការគ្រួសារ ក្រសួងសង្គមកិច្ច |
| ២១.លោក វ.ឯក | កែវ ជា | ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ២២.លោក | GARY WYNCEL | AFP-SLO( Australian Federal Police |
| ២៣.លោក | Sarom Seila | AFP ( Autralia Embassy ) |
| ២៤.លោកស្រី | Lauren Tuohy | Australia Embassy |
| ២៥.លោកស្រី | KIM LAMB | Australia Embassy |